# កាព្យច្បាប់ស្រី

*ជាព្រះរាជនិពន្ធនៃ ព្រះបាទសម្តេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ (ព្រះអង្គដួង) ដែលទ្រង់និពន្ធក្នុងឆ្នាំរកានព្វស័ក ព. ស. ២៣៨០ កាលព្រះអង្គមានព្រះជន្មគម្រប់ ៤១ វស្សា យកមកចុះទុកជាព្រះកេរ្តិ៍ក្នុងវចនានុ-ក្រមខ្មែរនេះ ចំពោះតែត្រង់កាព្យថ្លែងអំពីប្រពន្ធមាន ៧ ប្រភេទ ល្អបួនអាក្រក់បី, មិនវែងណាស់ណាទេ, ដូចតទៅនេះគឺ មួយសោតព្រះពុទ្ធ ទេស្នា ចំហុត ជារីករិយា មា នប្រាំពីរស្មោះ បួននោះចិត្តជា បីនោះមោហា ចិត្តខូចរាយដាយះ ឯប្រពន្ធជា ឯកឈ្មោះមាតា- ភរិយាដូចម្តាយ ឈឺឆ្អាលកូនខ្លួន វែងសួនមិនណាយ មិននឹករសាយ ចិត្តចាំអាណិត ។ កូនទុក្ខទោសម្តេច ខ្សត់ក្រច្រើនតិច ខឹងខុសខូចចិត្ត ព្រាត់ប្រាស់យូរលង់ ពុំបង់បែកចិត្ត គង់ចាំចិត្តគិត ឈឺឆ្អាលកូនស្មោះ ។ ប្រពន្ធណាគាប់ ឈឺឆ្អាលប្តីខ្ជាប់ ចិត្តចាំកាន់កោះ ដូចម្តាយស្រឡាញ់ កូនពេញពីពោះ ហៅប្រពន្ធនោះ ថ្លៃឥតផ្ទឹមដល់ ។ ប្រពន្ធជាទី ឈ្មោះហៅទាសី- ភរិយាដូចកល់ ខ្ញុំនឹងអម្ចាស់ ប្រើណាស់ខ្វាយខ្វល់ អាចមត់ទប់ទល់ ទមូន់បម្រើ ។ មិនមានទំនេរ ទោះម្ចាស់វាយជេរ អត់ឱនស័រពើ តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ ចៀសវាងក្រោធា ។ ប្រពន្ធណាអត់ ឱនអង្គអំណត់ ខ្វាចប្តីអាត្មា ដូចខ្ញុំនឹងម្ចាស់ ខ្វាចណាស់ធានា ប្រពន្ធនោះជា ប្រសើរសុខសូន្យ ។ ប្រពន្ធជាត្រី ឈ្មោះភគិនី- ភរិយាដូចប្អូន ស្រឡាញ់បងពិត លំអិតលំអូន ទទួលដំបូន- មានមាត់ពាក្យបង ។ ផ្តាច់ផ្តួលតែមួយ នឹងចងជាត្រួយ ចិត្តចាំបំណង ពំនាក់ពំនឹង ពាក់ពឹងប៉ុនប៉ង តែនឹងអង្គបង ឥតម៉ែទីទៃ ។ ប្រពន្ធណាចូល នឹងប្តីមួយមូល- ចិត្តជាប់អាល័យ ដូចប្អូននឹងបង ចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃ មធ្យមពេកពិត ។ ប្រពន្ធចត្វា ឈ្មោះហៅសខា- ភរិយាដូចមិត្រ- សំឡាញ់ស្រឡាញ់ អស់អញពេកពិត ស្មើខ្លួនស្មើចិត្ត ស្ម័គ្រស្មោះចិន្តា ។ បើមិត្រទៅបាត់ ស្ងប់ស្ងួតមុខមាត់ ទុក្ខទន់ទយា ឃើញ*

*មុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ ស្រួលកត្រា និរទុក្ខសោកសៅ ។ ប្រពន្ធណាចិត្ត ស្រឡាញ់ប្ដីពិត គ្មានក្នុងគ្មានក្រៅ ដូចមិត្រនិងមិត្រ ចងចិត្តជាប់នៅ ប្រពន្ធនោះហៅ ឧត្តមក្រមាន ។ សម្ដែងភរិយា ទាំងបួនសឹងជា ក្រស្រីធ្វើបាន បើស្រីណាគិតផ្ចង់ចិត្តសន្ដាន ស្រឡាញ់ប្ដីប្រាណ ដូចធម៌ទេស្នា ។ លោកថាស្រីនោះ ឮកេរ្ដិ៍ពីរោះទូទៅនានា បើអស់ជីវិត នៅឋិតសួគ៌ា ចៀសចាកចតុរា- បាយបាបទុក្ខភ័យ ។ ប្រពន្ធពុំជា ឈ្មោះវធកា- ភរិយាដូចនៃ សត្រូវចាំចង ទោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ ប្ដីមានតែទុក្ខ បើប្ដីខុសចិត្ត វាគ្មានអាណិត ខេរខឹងប្រអុក ចាំចងទោសប្ដី ស្រដីកិកកុក ឲ្យមាត់ឲ្យមុខ វាសវាងភ្លោះភ្លើយ ។ សុខទុក្ខសាំទាំ វាមើលបំណាំ នៅស្ងៀមព្រងើយ ពុំជួយទុក្ខភ័យ ដោះ ដៃកន្តើយ ស្ងាប់ដោយរស់ដោយ គ្មានចិត្តមេត្រី ។ ចោរីភរិយាប្រពន្ធពុំជា លប លួចទ្រព្យប្ដី គ្មានចិត្តករុណា មេត្តា ប្រណី របស់ទ្រព្យអ្វី លក់ចាយអស់ធួន ។ អយ្យាភរិយា ប្រ ពន្ធពុំជា តម្កើងតែខ្លួន ចេះតែប្រើប្ដី ឥតបីមានស្ងួត ធ្វើឫកណាំនួន ទុកប្ដីដូចខ្ញុំ ។ ប្រពន្ធទាំងបី ធ្លាក់ទៅអវិចី រងទុក្ខដំណំ ក្នុងខ្ទះភ្លើងក្ដៅយូរនៅក្រៀមក្រំ ព្រោះចិត្តខ្លួនធំ ជាងប្ដីអាត្មា ។ ឯប្រពន្ធបួន- មុខនោះគួរស្ងួន យកជាភរិយា នឹងកើតរបស់ កេរ្ដិ៍យសសក្ដា ថ្កើងពូជពង្សា សោយសុខថេរឋិត ។ សំដែងបរិយាយ ភរិយាទាំងឡាយ ប្រាំពីរចរិត ទាំងដួទាំងជា ពណ៌នាពោលពិត ចែងចប់ពិនិត្យ តាម អត្ថគាថា ។៚ (អ្នកមានព្យាយាម, បើពេញចិត្តចំពោះព្រះរាជនិពន្ធនេះ, គួរទន្ទេញឲ្យចាំមាត់, ឬបង្ហាប់កូនចៅតូចៗ ឲ្យទន្ទេញចាំស្ទាត់ ហើយឲ្យនាំគ្នាសូត្ររឿយៗ ដើម្បីរំលឹកគ្នាក្នុងគ្រួសារ ក៏ជាការប្រពៃណាស់) ។*

«ដកស្រង់ចេញពីវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន ណាត** ត្រង់ពាក្យថា «ប្រពន្ធ» »

*ភិក្ខុ ស្វាត សាលឿម*